**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៩-០១២-៣៥៤ សជណ

ភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២

**ជម្រាបមក**

**លោកនាយកក្រុមហ៊ុន ខេអេច អិនធី ហ្គោល**

**កម្មវត្ថុ** : ការដកហូតអាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃរបស់ក្រុមហ៊ុន ខេអេច អិនធី ហ្គោល ។

**យោង** : -ប្រកាសលេខ ធ៩.០៩.២៦២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១២ ស្តីពី "ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុនិងត្បូងថ្មមានតម្លៃ" ។

- សេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជាជូនដល់គ្រប់ក្រុមហ៊ុនប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ លេខ ធ៩.០១២.១០៣ សជណ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកក្រុមហ៊ុនជ្រាបថា គ្រប់ក្រុមហ៊ុនប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តតាមខ្លឹមសារប្រកាសស្តីពី"ការផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូលលោហធាតុនិងត្បូងថ្មមានតម្លៃ" និងការណែនាំផ្សេងៗទៀតដែលបានបញ្ជាក់នៅលើខ្នងនៃអាជ្ញាប័ណ្ណដែលបានផ្តល់ជូន ។ ក្រុមហ៊ុន ខេអេច អិនធីហ្គោល បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅខែធ្នូ ឆ្នាំ២០១០ ប៉ុន្តែរហូតមកដល់ពេលនេះ ក្រុមហ៊ុនមិនបានគោរពតាមលក្ខខណ្ឌនៃប្រកាសដោយខកខានមិនបានបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ និងមិនបានប្រតិបត្តិតាមសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជាដោយមិនបានផ្ញើរបាយការណ៍ប្រចាំខែ ទោះបីជាធនាគារជាតិធ្លាប់បានណែនាំជាច្រើនដងហើយក្តី។

អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជា សូមដកហូតអាជ្ញាប័ណ្ណចាប់ពីថ្ងៃចុះហត្ថលេខានេះ ។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសាភិបាលរង**

**អ៊ុក ម៉ាលី**